# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ ៣៧/០៣ ក.ក

# ប្រធានតុលាការកំពូល

## ជម្រាបមក

## លោកប្រធានតុលាការក្រុងភ្នំពេញ

**កម្មវត្ថុ:** អំពីការដោះស្រាយបណ្តឹងដិតចិត្ត ចំពោះអនុប្រធាន និង ចៅក្រមតុលាការ ក្រុងភ្នំពេញ ។

កន្លងមកតុលាការកំពូល បានទទួលនូវបណ្តឹងដិតចិត្តជាច្រើន ពីចៅក្រម នៃតុលាការក្រុងភ្នំពេញដែលតាមមាត្រា៣៤ ច្បាប់ស្តីពី នីតិវិធីជំនុំជម្រះផ្នែកព្រហ្មទណ្ឌ បណ្តឹងនេះលោកជាប្រធានតុលាការជាអ្នកសម្រេច ។ ប៉ុន្តែតុលាការកំពូលសង្កេតឃើញថា ក្នុងការសម្រេពីបណ្តឹងនេះលោកពុំទាន់អនុវត្តបានល្អតាមគោលការណ៍ច្បាប់ទេ ។ ជាគោលការណ៍បើមានបណ្តឹងដិតចិត្តលើចៅក្រមណាម្នាក់ គប្បីលោកប្រធានរួសរាន់ដោះស្រាយឱ្យបានឆាប់ដែលអាចធ្វើទៅបាន ។

-ការសម្រេចអំពីបណ្តឹងដិតចិត្ត មិនមែនផ្អែកតែលើឆន្ទៈ រឺ យោបល់ទាំងស្រុងរបស់ចៅក្រម ដែលត្រូវគេប្តឹងនោះទេ គឺត្រូវផ្អែកជាសំខាន់លើមូលហេតុ និងភស្តុតាងរបស់ម្ចាស់បណ្តឹង ដើម្បីសម្រេចថា ត្រូវឱ្យផ្លាស់ប្តូរចៅក្រមកាន់សំណុំរឿងចេញ រឺ មិនផ្លាស់ប្តូរ ។

-ក្រោយពេលសម្រេចអំពីបណ្តឹងដិតចិត្តនេះហើយ ត្រូវជូនដំណឹងដល់សាមីម្ចាស់បណ្តឹងដើម្បីឱ្យគេដឹងថាតើបណ្តឹងរបស់គេត្រូវបានទទួល រឺ បដិសេធ ។ ក្នុងករណីបដិសេធ ត្រូវផ្តល់នូវសំអាងហេតុ ។

-មិនគប្បីបិតនៅក្នុងសភាពស្ងាត់ស្ងៀម ដោយមិនឱ្យដំណឹងអ្វីទាំងអស់ដល់ម្ចាស់បណ្តឹងឡើយ ។

សូមលោកប្រធានទទួលនូវការរាប់អានអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣

**ឌិត មុន្ទី**

ចម្លងជូន

-គ្រប់តុលាការខេត្ត-ក្រុង

-ឯកសារ